Organized by

Supported by

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin



## Inside

### Infographic
"Exporting Under Cambodia-Korea FTA: Information Exporter Need to Know"

### Policy Brief
"Global Value Chain, Cities and Urban Amenities: Next Stage of Growth for ASEAN and East Asia"

*Shandre Mugan Thangavelu*
*Fukunari Kimura*
*Dionisius A. Narjoko*

វ៉ុល០៣ | លេខ០១ | ខែមករា ឆ្នាំ២០២៣
VOLUME 03 | ISSUE 01 | JANUARY 2023

# ការនាំចេញក្រោម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ

## ព័ត៌មានដែលអ្នកនាំចេញត្រូវដឹង

រៀបចំដោយ

គាំទ្រដោយ



## ១ ការប្រើប្រាស់នៃការបូកបន្ថែមវត្ថុធាតុដើម និងការដឹកជញ្ជូនដោយផ្ទាល់

### CKFTA

- អនុញ្ញាតឱ្យប្រើប្រាស់ការបូកបន្ថែមវត្ថុធាតុដើមពីកម្ពុជា និងកូរ៉េខាងត្បូង រាប់ជាសមាសធាតុដើម
- ការដឹកជញ្ជូនគ្មានលក្ខខណ្ឌភូមិសាស្ត្រ និងការទាមទារបញ្ជាក់ភស្តុតាងជាមួយឯកសារគយដាច់ដោយឡែក (សូមមើលលម្អិតក្នុងជំពូកទី៣ មាត្រា៣.៩)

** CKFTA = កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-កូរ៉េ*

### RCEP

- អនុញ្ញាតឱ្យប្រើប្រាស់ការបូកបន្ថែមវត្ថុធាតុដើមពីប្រទេសទាំង១៥ (អាសិប) រាប់ជាសមាសធាតុដើម
- ការដឹកជញ្ជូនការទាមទារបញ្ជាក់ភស្តុតាងជាមួយឯកសារគយ និងបញ្ជាក់ឱ្យច្បាស់នៅក្នុងលក្ខខណ្ឌនៃឯកសារ (សូមមើលលម្អិតក្នុងជំពូកទី៣ មាត្រា៣.១៥)

** RCEP = កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ*

### AKFTA

- អនុញ្ញាតឱ្យប្រើប្រាស់ការបូកបន្ថែមវត្ថុធាតុដើមពីប្រទេសអាស៊ាន រាប់ជាសមាសធាតុដើម
- ការដឹកជញ្ជូនទាមទារយុត្តិកម្មសម្រាប់ហេតុផលភូមិសាស្ត្រ និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលគយ (សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធទី៣ វិធាន៩)

** AKFTA = កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ*

## តើធ្វើដូចម្ដេចដើម្បីកំណត់វិធានប្រភពដើមនៃកិច្ចព្រមព្រៀង CKFTA?

អ្នកនាំចេញអាចអនុវត្តតាមជំហានទាំងនេះដើម្បីកំណត់វិធានប្រភពដើម នៃកិច្ចព្រមព្រៀង CKFTA

- ការកំណត់ប្រទេសគោលដៅនាំចេញ
- ពិនិត្យទំនិញស្ថិតនៅលេខកូដ HS មួយណា
- អនុលោមតាមតម្រូវការក្រោមឧបសម្ព័ន្ធ 3-A នៃកិច្ចព្រមព្រៀង CKFTA

## ការចុះឈ្មោះសម្រាប់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

អ្នកនាំចេញតម្រូវឱ្យចុះឈ្មោះគណនីអ្នកប្រើប្រាស់នៅក្នុងប្រព័ន្ធ (https://co.moc.gov.kh) ដោយបញ្ចូលព័ត៌មានដូចខាងក្រោម៖

- ចុះឈ្មោះក្រុមហ៊ុន និងអាសយដ្ឋាន
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ស្កេនច្បាប់ចម្លងដើម)
- វិញ្ញាបនបត្រនៃការចុះឈ្មោះ GSP/MFN (ស្កេនច្បាប់ចម្លងដើម)
- បញ្ជីទំនិញនាំចេញ
- លិខិតអនុញ្ញាតពីអ្នកនាំចេញ (ស្កេនច្បាប់ចម្លងដើម)
- អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនរបស់អ្នកផ្ដល់សិទ្ធិ និងបុគ្គលដែលទទួលបានសិទ្ធិ និងរូបថត
- ឯកសារផ្សេងទៀត ប្រសិនបើតម្រូវដោយច្បាប់/បទប្បញ្ញត្តិ (ស្កេនច្បាប់ចម្លងដើម)

សូមស្កេនដើម្បីទាញយកព្រឹត្តិបត្រពាណិជ្ជកម្ម

## ២ លក្ខណៈវិនិច្ឆ័យដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

ដើម្បីទទួលបានវិញ្ញាបនបត្រប្រភពដើមពីកិច្ចព្រមព្រៀង CKFTA អ្នកនាំចេញត្រូវពិចារណាវិធានប្រភពដើមដូចខាងក្រោម៖




## ៣ នីតិវិធីនាំចេញ និងទទួលវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

បន្ទាប់ពីការចុះឈ្មោះរួចហើយ អ្នកនាំចេញត្រូវដាក់ពាក្យស្នើសុំតាមប្រព័ន្ធអនឡាញសម្រាប់ទទួលវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (CO) ដោយបញ្ចូលព័ត៌មានដូចខាងក្រោម៖

- វិក្កយបត្រ
- តារាងវេចខ្ចប់
- តារាងថ្លៃដើមផលិតផលឬឯកសារយោង *(ប្រសិនបើតម្រូវដោយវិធានប្រភពដើម)*
- របាយការណ៍អធិការកិច្ចលើសម្លៀកបំពាក់ ទំនិញឆ្លងកាត់ ឬទំនិញដឹកជញ្ជូនដំបូង
- ឯកសារផ្សេងទៀតដែលតម្រូវដោយប្រទេសនាំចូលដើម្បីអនុលោមតាមវិធានប្រភពដើម

### ដំណើរការស្វ័យប្រវត្តិកម្មនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ



# EXPORTING UNDER CAMBODIA-KOREA FTA

## Information Exporters Need to Know

Organized by

Supported by



## How to Determine ROO of CKFTA?

Exporter may follow these steps to determine ROO of CKFTA.

- Determine destination countries
- Identify Products Harmonized System Codes (HS Code)
- Comply with Requirements under Annex 3-A of CKFTA

## Registration for CO

Exporter is required to register for user account in the system (https://co.moc.gov.kh) by uploading:

- Register the company name and address
- Certificate of business registration (Original copy scan)
- Certificate of GSP/MFN registration (Original copy scan)
- List of exported goods
- Authorization letter from exporter (Original copy scan)
- ID/passport of authorization person and authorized person and photo
- Other documents, if required by law/regulation (Original copy scan)

Scan to download iTrade Bulletin

## 1 Cumulation of Raw Materials & Direct Consignments

### CKFTA

- Allows cumulation of raw materials from Cambodia and South Korea to count as originating content.
- No geographical reason condition, mention required evidenced with customs documents in separated articles. *(See detail in Chapter 3 Article 3.9)*

### RCEP

- Allows cumulation of raw materials from all 15 countries to count as originating content.
- Requires evidenced with customs documents, provide clarity in terms of appropriate documents. *(See detail in Chapter 3 Article 3.15)*

### AKFTA

- Allows cumulation of raw materials from ASEAN and South Korea to count as originating content.
- Requires justification for geographical reason, not mentioned under the control of the customs administration *(See detail in Annex3 Rule9)*

** CKFTA = Cambodia-Korea Free Trade Agreement*
** RCEP = Regional Comprehensive Economic Partnership*
** AKFTA = ASEAN-Korea Free Trade Agreement*

## 2 Qualification to Acquire Certificate of Origin of CKFTA

To acquire certificate of origin of CKFTA, exporter has to consider the ROO as follows:




## 3 Export Procedures - CO Application & Process

After registration, exporter has to submit online application for CO by uploading:

- Invoice
- Packing List
- Cost Breakdown or reference document *(if required by ROO)*
- Inspection report on camouflage garment, transit goods or first shipment goods
- Other documents required by importing country to comply with ROO

### CO Automation Process



## សម្តេចនាយករដ្ឋមន្ត្រីដំណើរនិវត្តន៍ពីម៉ាល់ឌីវជាមួយលទ្ធផលដ៏ត្រចះត្រចង់

បន្ទាប់ពីដំណើរទស្សនកិច្ចផ្លូវការរយៈពេលបីថ្ងៃនៅសាធារណរដ្ឋម៉ាល់ឌីវ គណៈប្រតិភូជាន់ខ្ពស់កម្ពុជាដឹកនាំដោយ**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានដំណើរនិវត្តន៍មកកម្ពុជាវិញជាមួយលទ្ធផលដ៏ត្រចះត្រចង់។ អំឡុងពេលទស្សនកិច្ចនេះ កម្ពុជា និងម៉ាល់ឌីវបានចុះហត្ថលេខាលើលិខិតតុបករណ៍ចំនួនប្រាំមួយរួមមានការលើកលែងទិដ្ឋាការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទេសចរណ៍និងសុខាភិបាល កិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេស នៃប្រទេសទាំងពីរ អនុស្សរណៈយោគយល់គ្នារវាងសភាពាណិជ្ជកម្មជាតិ និងឧស្សាហកម្មម៉ាល់ឌីវ និងសភាពាណិជ្ជកម្មកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាក៏បានប្រកាសពីការតែងតាំងឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌាឱ្យទទួលបន្ទុកជាឯកអគ្គរាជទូតប្រចាំម៉ាល់ឌីវ និងជ្រើសរើសផ្លូវមួយខ្សែនៅទីក្រុងមាត់សមុទ្រកម្ពុជា ដោយដាក់ឈ្មោះថា ផ្លូវមិត្តភាពកម្ពុជា-ម៉ាល់ឌីវ ដើម្បីបើកទំព័រថ្មី នៃការលើកកម្ពស់ចំណងមិត្តភាពរវាងប្រទេសទាំងពីរឱ្យកាន់តែជិតស្និទ្ធ។ *ប្រភព៖ Khmer Times*

## ទំហំពាណិជ្ជកម្មកម្ពុជាជាមួយសមាជិកអាសិប ឈានដល់ ៣១ប៊ីលានដុល្លារក្នុងឆ្នាំ២០២២

យោងតាមរបាយការណ៍ ក្រសួងពាណិជ្ជកម្មកម្ពុជា ទំហំពាណិជ្ជកម្មកម្ពុជា ជាមួយប្រទេសសមាជិកអាសិបមានចំនួន ៣១ ប៊ីលានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ កើនឡើង ៤%ធៀបនឹងឆ្នាំមុន។ ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសសមាជិកអាសិបមានចំនួន ៦,៣៤ ប៊ីលានដុល្លារ កើនឡើង៧% ខណៈដែលការនាំចូលមានចំនួន២៤,៦៨ ប៊ីលានដុល្លារកើនឡើង ៣%។ ប្រទេសចំនួន ៥ ដែលជាដៃគូពាណិជ្ជកម្មធំៗរបស់កម្ពុជាក្រោមក្របខ័ណ្ឌអាសិបគឺ ចិន វៀតណាម ថៃ សិង្ហបុរី និងជប៉ុន។ ឯកឧត្តម ប៉ែន សុវិជាតិ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ថា កំណើនទំហំពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសសមាជិកអាសិបមានកម្រិតមធ្យមនៅឡើយ ដោយសារប្រទេសទាំងអស់ទើបតែងើបចេញពី វិបត្តិជំងឺកូវីដ-១៩។ ឯកឧត្តមបានបន្ថែមថា "យើងជឿជាក់ថាកំណើននេះនឹងមានការកើនឡើងបន្ថែមទៀតក្នុងឆ្នាំនេះ និងឆ្នាំបន្តបន្ទាប់។ អាសិបគឺកាតាលីករ សម្រាប់កំណើនពាណិជ្ជកម្មរយៈពេលវែង និងមាននិរន្តភាព ហើយកិច្ចព្រមព្រៀងនេះ គឺជាដែកឆក់មួយ សម្រាប់ស្រូបទាញការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា"។ *ប្រភព៖ Khmer Times*

## ការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាមានកំណើនជាមធ្យម ៨,១% ពីឆ្នាំ២០១៧ ដល់២០២១

យោងតាមរបាយការណ៍និន្នាការពាណិជ្ជកម្ម និងវិនិយោគប្រទេសប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០២២-២០២៣ របស់គណៈកម្មាធិការសេដ្ឋកិច្ចសង្គមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (ESCAP) កម្ពុជាទទួលបានការវិនិយោគផ្ទាល់ពីបរទេស ក្នុងកំណើនជាមធ្យមប្រមាណ៨,១% ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១។ កំណើននេះមានអត្រាខ្ពស់ជាងកំណើនជាមធ្យម នៃការវិនិយោគផ្ទាល់ពីបរទេសមកតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានប្រមាណ ៣,៨%។ ទោះជាយ៉ាងណា ក្នុងឆ្នាំ២០២១ កម្ពុជាទទួលបានកំណើនវិនិយោគផ្ទាល់ពីបរទេសត្រឹមតែ ៣,៩% តែប៉ុណ្ណោះ។ របាយការណ៍ដដែលក៏បានបង្ហាញថា ថ្លៃធ្វើពាណិជ្ជកម្មកម្ពុជាជាមួយប្រទេសអាស៊ីបូព៌ាទាំងបី (ចិន ជប៉ុន និងកូរ៉េខាងត្បូង) មានកម្រិតទាបបំផុត។ "ក្នុងឆ្នាំ ២០២២ ថ្លៃធ្វើពាណិជ្ជកម្មជាមួយប្រទេសទាំងបីនេះ មានអត្រាជាមធ្យម៩៦,៤% នៃតម្លៃទំនិញ ធៀបនឹងពេលដែលប្រទេសទាំងនេះធ្វើពាណិជ្ជកម្មលើទំនិញទាំងនេះក្នុងប្រទេសពួកគេ"។ ដោយឡែក ថ្លៃធ្វើពាណិជ្ជកម្មមានអត្រាខ្ពស់ជាងនេះរវាងកម្ពុជា និងប្រទេសបីក្នុងតំបន់អឺរ៉ុប (អាល្លឺម៉ង់ បារាំង និងចក្រភពអង់គ្លេស)គឺប្រមាណ ១០៤,២% និងរវាងកម្ពុជាជាមួយប្រទេសកំពុងអភិវឌ្ឍន៍ធំៗ នៃតំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន ៤ (ចិន ឥណ្ឌា ឥណ្ឌូនេស៊ី និងរុស្ស៊ី) ដែលមានអត្រាប្រមាណ១៤៥,៤%។ *ប្រភព៖ Khmer Times*

## ការនាំចេញកៅស៊ូរបស់កម្ពុជាកើនឡើង ២៨% ក្នុងឆ្នាំ ២០២២

កម្ពុជារកចំណូលបាន៥៤១,៦៦ លានដុល្លារអាមេរិក ពីការនាំចេញជ័រកៅស៊ូ និងផលិតផលកៅស៊ូ នៅឆ្នាំ២០២២ ដែលមានកំណើន២៨,៣% ធៀបនឹងឆ្នាំមុន បើទោះបីជាមានស្ថានភាពមិនល្អ រួមទាំងការធ្លាក់ចុះនៃតម្លៃកៅស៊ូធម្មជាតិក៏ដោយ។ យោងតាមទិន្នន័យពាណិជ្ជកម្មដែលចេញផ្សាយដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នាពេលថ្មីៗនេះ ការនាំចេញផលិតផលកៅស៊ូមានចំនួន២,៤% នៃការនាំចេញសរុបក្នុងឆ្នាំ២០២២ ដែលប្រសើរជាងឆ្នាំ២០២១ បន្តិចដែលមានចំនួនត្រឹមតែ២,២%។ ទីផ្សារនាំចេញកៅស៊ូពីកម្ពុជាមានដូចជា ចិន វៀតណាម ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌា និងសហភាពអឺរ៉ុប។ *ប្រភព៖ Khmer Times*

### Cambodian PM Returns Home from Maldives with Fruitful Outcome

The high-level Cambodian delegation led by Prime Minister Hun Sen just concluded the three-day official visit in Maldives with fruitful outcome. During the visit, Cambodia and Maldives signed six important documents on visa exemption, economic, tourism and health cooperation, bilateral consultations between the Ministries of Foreign Affairs of both nations, and MoU between the Maldives National Chamber of Commerce and Industry (MNCCI) and the Cambodia Chamber of Commerce (CCC). The Royal Government of Cambodia also announced to appoint the Cambodian Ambassador to India as the Non-Resident Ambassador to Maldives, and to name a street in a Cambodian coastal city as Cambodia-Maldives Friendship Street to highlight the opening of a new page which will bring closer the bonds of friendship between the two countries. *Source: Khmer Times*

### Cambodia's Trade with RCEP Countries Hit $31 bln in 2022

Cambodia's trade with the Regional Comprehensive Economic Partnership (RCEP) member countries reached USD 31 billion in 2022, up 4 percent from a year earlier, according to a Ministry of Commerce report. The report said the kingdom's export to the RCEP countries amounted to USD 6.34 billion last year, up 7 percent, while its import from the RCEP countries totaled USD 24.68 billion, increasing 3 percent. Cambodia's top five trading partners under RCEP are China, Vietnam, Thailand, Singapore, and Japan, the report added. Cambodian Ministry of Commerce's Secretary of State and Spokesman PENN Sovicheat said Cambodia's trade growth with other RCEP countries was moderate because the kingdom and other countries alike have just recovered from the COVID-19 pandemic. "We believe that the growth will be higher this year and beyond," he told Xinhua. "RCEP is a catalyst for our long-term and sustainable trade growth and it is a magnet to attract more foreign direct investments to our country." *Source: Khmer Times*

### Average Annual FDI Inflow Growth of 8.1% in Cambodia from 2017 to 2021

Cambodia recorded an average annual FDI inflow growth of 8.1% from 2017 to 2021, according to the Asia-Pacific Trade and Investment Trends 2022-2023 Country Report for Cambodia by the UN Economic and Social Commission for Asia and the Pacific (ESCAP). The FDI inflows growth was higher than the Asia-Pacific's 3.8% average annual FDI inflows growth during the period. However, in 2021, the country experienced a decline in FDI inflows by 3.9%, it said. It also mentioned that Cambodia's trade costs were lowest with the East Asia-3 economies of China, Japan and South Korea. "In 2020, trade costs with the East Asia-3 economies, on average, amounted to 96.4% of the value of goods, as compared to when the countries traded these goods within their borders. Trade costs were higher with the Europe-3 economies (Germany, France and the UK) and large Asia-Pacific Developing-4 economies (China, India, Indonesia and Russia), amounting to 104.2% and 145.4%, respectively," it said. *Source: Khmer Times*

### Cambodia's Rubber Goods Exports up 28% in 2022

Cambodia earned USD 541.66 million from the export of rubber and rubber articles in 2022, recording a growth of 28.3% compared to the previous year, despite adverse conditions including a fall in the prices of natural rubber. According to the trade data released by the General Department of Customs and Excise (GDCE) recently, the exports of rubber articles constituted 2.4% of the total exports in 2022, slightly better than the 2.2% share in 2021. The Cambodian rubber market consists of China, Vietnam, Malaysia, Singapore, India, and the EU. *Source: Khmer Times*

## ផលិតភាពអាស៊ីត្រូវការការជំរុញបន្ថែមពីឌីជីថលនីយកម្ម

ខណៈកំណើនសេដ្ឋកិច្ចសកលកើនឡើងយឺត ការជំរុញការចាប់យកបច្ចេកវិទ្យា និងលុបបំបាត់គម្លាតឌីជីថល អាចជួយឱ្យតំបន់បង្កើនផលិតភាពសរុប និងទិន្នផលសេដ្ឋកិច្ចឡើងវិញបាន។ វិធីជោគជ័យសម្រាប់ជំរុញផលិតភាពរបស់តំបន់អាស៊ីគឺ ឌីជីថលភាវូបនីយកម្ម។ ទិដ្ឋភាពឌីជីថលនៅក្នុងតំបន់អាស៊ី បានរីកដុះដាលរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅមុនពេលមានជំងឺរាតត្បាត ក្រុមហ៊ុនចំនួន ៦០% ក្នុងតំបន់អាស៊ី ទទួលបានប្រកាសសនីយបត្រតក្កកម្មក្នុងវិស័យបច្ចេកវិទ្យាឌីជីថល និងកុំព្យូទ័រ ដែលចំនួននេះបានកើនប្រមាណ៤០% ធៀបនឹងពីទសវត្សរ៍មុន។ *ប្រភព៖ International Monetary Fund*

## ប្រទេសកំពុងអភិវឌ្ឍរងផលប៉ះពាល់ខ្លាំងពីកំណើនសេដ្ឋកិច្ចដែលបានធ្លាក់ចុះយ៉ាងខ្លាំង និងបន្តធ្លាក់ចុះក្នុងរយៈពេលយូរបន្ថែមទៀត

របាយការណ៍ចុងក្រោយ ស្តីពីទស្សនវិស័យសេដ្ឋកិច្ចសកលរបស់ធនាគារពិភពលោក បានបង្ហាញថាកំណើនសេដ្ឋកិច្ចសកលកំពុងធ្លាក់ចុះយ៉ាងខ្លាំង ក្រោយប្រឈមមុខនឹងវិបត្តិអតិផរណាកើនឡើង អត្រាការប្រាក់ខ្ពស់ សកម្មភាពវិនិយោគថយចុះ និងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។ សេដ្ឋកិច្ចសកល ត្រូវបានព្យាករណ៍ថានឹងកើនឡើងប្រមាណ១,៧% ក្នុងឆ្នាំ ២០២៣ និងប្រមាណ ២,៣% ក្នុងឆ្នាំ២០២៤។ ការធ្លាក់ចុះខ្លាំងនៃកំណើនសេដ្ឋកិច្ច ត្រូវបានគេរំពឹងថានឹងបន្តអូសបន្លាយបន្ថែមទៀត។ ក្នុងរយៈពេលពីរឆ្នាំខាងមុខកំណើនប្រាក់ចំណូលរបស់ប្រជាជនម្នាក់ៗ ក្នុងទីផ្សារកំពុងរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍ ត្រូវបានគេព្យាករណ៍ថា មានអត្រាជាមធ្យមប្រមាណ២,៨% ដែលជាកំណើនក្នុងអត្រាទាបធៀបនឹងកំណើនចន្លោះឆ្នាំ២០១០-២០១៩។ នៅចុងឆ្នាំ ២០២៤ កម្រិតផលិតផលក្នុងស្រុកសរុបនៃទីផ្សារកំពុងរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍ នឹងមានអត្រាកំណើនប្រមាណ៦% ក្រោមកម្រិតដែលត្រូវបានរំពឹងទុកមុនពេលមានជំងឺរាតត្បាត។ *ប្រភព៖ World Bank*

## ការលុបបំបាត់របាំងពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍ

ប្រទេសជាសម្ព័ន្ធមិត្ត បានបង្កើតវិធីសាស្ត្រពិសេសមួយក្នុងគោលបំណងធានាប្រសិទ្ធភាព ក្នុងការផ្តល់ជំនួយសម្រាប់ពាណិជ្ជកម្ម ដោយផ្អែកលើគោលការណ៍បី៖ ប្រើប្រាស់ជំនាញ និងការយល់ដឹងពីវិស័យឯកជនក្នុងការរួមចំណែកយ៉ាងសកម្មក្នុងការជំនះឧបសគ្គពាណិជ្ជកម្ម កសាងរចនាសម្ព័ន្ធប្រតិបត្តិការដែលមានភាពរហ័សរហួន និងឆ្លើយតប និងវាស់វែងបរិមាណផលប៉ះពាល់នៃការងារដែលបានអនុវត្តជាក់ស្តែង។ លើសពីនេះ សមាជិកបានផ្តោតលើការជំរុញនវានុវត្តន៍ តាមរយៈគំនិតផ្តួចផ្តើមមួយចំនួន រួមមាន ការធ្វើជាម្ចាស់ផ្ទះ នៃការសម្ពោធកម្មវិធីនវានុវត្តន៍ក្នុងកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមកិច្ចសហការជាមួយសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) ក្នុងគោលបំណងពង្រឹង និងគិតឡើងវិញនូវមធ្យោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មឆ្លងព្រំដែន។ គំនិតផ្តួចផ្តើមតាមអ៊ីនធឺណិតនេះ បានទាក់ទាញអ្នកចូលរួមជិត៧០០ នាក់មកពីជាង១០០ ប្រទេស រួមទាំងអ្នកជំនាញការកិច្ចសម្រួលពាណិជ្ជកម្ម មន្ត្រីរដ្ឋាភិបាល ភ្នាក់ងារព្រំដែន អ្នកដឹកជញ្ជូន អ្នកសិក្សា និងអ្នកជំនាញផ្សេងទៀត។ *ប្រភព៖ World Economic Forum*

## ការប្រឈមមុខនឹងការបែកខ្ញែកដែលវាសំខាន់ជាងគេ៖ ពាណិជ្ជកម្ម បំណុល និងវិធានការលើអាកាសធាតុ

នៅពេលដែលអ្នកបង្កើតគោលនយោបាយ និងអ្នកដឹកនាំធុរកិច្ចជួបប្រជុំគ្នា នៅវេទិកាសេដ្ឋកិច្ចពិភពលោកនៅទីក្រុង Davos ពួកគេកំពុងប្រឈមមុខនឹងបញ្ហាស្មុគស្មាញ។ រាប់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងការប្រែប្រួលអាកាសធាតុ រហូតដល់វិបត្តិថ្លៃនៃការរស់នៅ និងកម្រិតបំណុលខ្ពស់៖ មិនមានវិធីងាយស្រួលដើម្បីដោះស្រាយទេ។ បន្ថែមលើនេះ គឺភាពតានតឹងភូមិសាស្ត្រនយោបាយ ដែលធ្វើឱ្យបញ្ហាសកលទាំងនេះ កាន់តែលំបាកក្នុងការដោះស្រាយ។ ជាការពិតណាស់ ទោះបីជាយើងត្រូវការកិច្ចសហប្រតិបត្តិការអន្តរជាតិបន្ថែមទៀតលើផ្នែកជាច្រើនក៏ដោយ ក៏យើងកំពុងប្រឈមមុខនឹងទិដ្ឋភាព នៃសង្គ្រាមត្រជាក់ថ្មី

ដែលកំពុងបែងចែកពិភពលោក ទៅជាប្លុកសេដ្ឋកិច្ចប្រជែងគ្នា។ នេះជាកំហុសគោលនយោបាយសមូហភាព ដែលនឹងធ្វើឱ្យគ្រប់គ្នាកាន់តែក្រ និងមិនសូវមានសុវត្ថិភាព។ *ប្រភព៖ International Monetary Fund*

## មន្ត្រីជាន់ខ្ពស់អាម៉េរិក និងចិនបានជួបពិភាក្សាគ្នាលើបញ្ហាអាកាសធាតុ សេដ្ឋកិច្ច និងទំនាក់ទំនង

រដ្ឋមន្ត្រីរតនាគារជាតិអាម៉េរិក លោកស្រី Janet Yellen បានជួបជាមួយឧបនាយករដ្ឋមន្ត្រីចិន លោក Liu He នៅទីក្រុងហ្សូរីច កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ និងបានសន្យាថានឹងខិតខំប្រឹងប្រែង ដើម្បីគ្រប់គ្រងភាពខុសគ្នានិង "ទប់ស្កាត់ការប្រកួតប្រជែងមិនឱ្យក្លាយជាជម្លោះ" ខណៈប្រទេសទាំងពីរ ព្យាយាមធ្វើឱ្យទំនាក់ទំនងកាន់តែល្អប្រសើរឡើងវិញ។ របាយការណ៍សង្ខេបរបស់រតនាគារជាតិអាម៉េរិកនៃកិច្ចប្រជុំរយៈពេល២ ម៉ោង ៣០នាទីឱ្យដឹងថាភាគីទាំងពីរបានព្រមព្រៀងគ្នាថា សហរដ្ឋអាម៉េរិក និងចិននឹងសហការបន្ថែមទៀតលើបញ្ហាជុំវិញការផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងធ្វើការដើម្បីគាំទ្រដល់ "ប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងអន្តរកម្មនៃការប្រើប្រាស់ថាមពលស្អាត"។ របាយការណ៍សង្ខេបនេះក៏បង្ហាញផងដែរថា លោកស្រី Yellen គ្រោងនឹងធ្វើដំណើរទៅកាន់ប្រទេសចិន និងស្វាគមន៍សមភាគីចិនមកកាន់សហរដ្ឋអាម៉េរិកនាពេលខាងមុខនេះ។ *ប្រភព៖ AP News*

## ពាណិជ្ជកម្មរវាងអាម៉េរិកនិងចិន ជិតឈានដល់កំណត់ត្រាខ្ពស់មួយ ផ្ទុយពីការយល់ឃើញអំពីការផ្តាច់ទំនាក់ទំនង

ពាណិជ្ជកម្មរវាងអាម៉េរិកនិងចិនកំពុងស្ថិតនៅលើកំណត់ត្រាខ្ពស់មួយ ដែលជាសញ្ញានៃទំនាក់ទំនងដ៏រឹងមាំរវាងមហាអំណាចសេដ្ឋកិច្ចទាំងពីរ ស្របពេលដែលមានការលើកឡើងពីសន្តិសុខជាតិដ៏ក្តៅគគុកនៅអាម៉េរិកនិងការភ័យខ្លាចនៃការផ្តាច់ទំនាក់ទំនង។ ទិន្នន័យរបស់រដ្ឋាភិបាលអាម៉េរិកត្រឹមខែវិច្ឆិកា ឆ្នាំ២០២២ បង្ហាញថា ការនាំចូលនិងការនាំចេញនៅឆ្នាំ២០២២ នឹងកើនឡើងដល់កម្រិតខ្ពស់បំផុត ឬយ៉ាងហោចណាស់ក៏ជិតដល់កម្រិតខ្ពស់បំផុតដែរ នៅពេលដែលរបាយការណ៍ចុងក្រោយនឹងចេញផ្សាយនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។ ប្រទេសចិនទើបតែបានចេញផ្សាយតួលេខឆ្នាំ២០២២របស់ខ្លួនដែលបង្ហាញថាការធ្វើពាណិជ្ជកម្មដែលមានតម្លៃប្រហែល ៧៦០ ប៊ីលានដុល្លារ។ សញ្ញាវិជ្ជមាននាពេលថ្មីៗនេះ រួមទាំងកិច្ចប្រជុំទល់មុខគ្នាលើកដំបូងក្នុងខែវិច្ឆិកា ឆ្នាំ២០២២ រវាងប្រធានាធិបតីអាម៉េរិក លោក ចូ បៃដិន និងមេដឹកនាំចិន លោក ស៊ី ជីនពីង និងគម្រោងទស្សនកិច្ចរបស់មន្ត្រីជាន់ខ្ពស់អាម៉េរិក លោករដ្ឋមន្ត្រី អាន់តូនី ប្លីនកេន ទៅកាន់ប្រទេសចិនក្នុងឆ្នាំនេះ។ ប៉ុន្តែមហាអំណាចសេដ្ឋកិច្ចទាំងពីរហាក់ដូចជាមិនងាយនឹងដោះស្រាយការខ្វែងគំនិតគ្នាងាយស្រួលនោះទេ រួមទាំងជំហររបស់ចិនចំពោះកោះតៃវ៉ាន់ និងសមុទ្រចិនខាងត្បូង ក៏ដូចជាវិធានការដ៏ខ្លាំងក្លារបស់អាម៉េរិកក្នុងការរឹតបន្តឹងចិនក្នុងការចូលប្រើប្រាស់បច្ចេកវិទ្យា semiconductor សំខាន់ៗ។ នេះបង្ហាញពីភាពជាប់ពាក់ព័ន្ធគ្នាយ៉ាងស៊ីជម្រៅនៃមហាអំណាចសេដ្ឋកិច្ចទាំងពីរ បើទោះបីជាអាម៉េរិកមានគោលបំណងរារាំងការជឿនលឿនរបស់ចិន ហើយចិនស្វែងរកការប្រឆាំងនឹងឥទ្ធិពលសកលរបស់រដ្ឋអាម៉េរិកក៏ដោយ។ *ប្រភព៖ Bloomberg*

### Asia's Productivity Needs a Boost That Digitalization Can Provide

Amid slowing global growth, promoting technological adoption and closing digital divides can help the region boost aggregate productivity and economic output. There is a promising path for boosting Asia's productivity: digitalization. Asia's digital landscape has swelled in recent years. The region accounted for 60% of patents in digital and computer technologies right before the pandemic, up from 40% two decades earlier. *Source: International Monetary Fund*

### Sharp, Long-lasting Slowdown to Hit Developing Countries Hard

Global growth is slowing sharply in the face of elevated inflation, higher interest rates, reduced investment, and disruptions caused by Russia’s invasion of Ukraine, according to the World Bank’s latest Global Economic Prospects report. The global economy is projected to grow by 1.7% in 2023 and 2.7% in 2024. The sharp downturn in growth is expected to be widespread, with forecasts in 2023 revised down for 95% of advanced economies and nearly 70% of emerging market and developing economies. Over the next two years, per-capita income growth in emerging market and developing economies is projected to average 2.8%—a full percentage point lower than the 2010-2019 average. By the end of 2024, GDP levels in emerging and developing economies will be roughly 6% below levels expected before the pandemic. *Source: World Bank*

### Removing Trade Barriers in the Developing World

The Alliance has developed a unique methodology aimed at being more effective in delivering aid for trade based on three principles: leveraging the expertise and insight of the private sector in actively contributing to overcoming trade barriers; building an operational structure which is agile and responsive; and quantitatively measuring the impact of work carried out on the ground. Additionally, the Alliance has focused on pushing innovation through a number of initiatives including the hosting of the inaugural Trade Facilitation Innovation Days in partnership with UNCTAD aimed at reinvigorating and reimagining ways of streamlining cross-border trade. The online initiative attracted almost 700 participants in over 100 countries, including trade facilitation experts, government officials, border agents, logisticians, academics, and other specialists. *Source: World Economic Forum*

### Confronting Fragmentation Where It Matters Most: Trade, Debt, and Climate Action

As policymakers and business leaders gather at the World Economic Forum in Davos, they are facing a Gordian knot of challenges. From the global economic slowdown and climate change to the cost-of-living crisis and high debt levels: there is no easy way to cut through it. Added to this are geopolitical tensions that have made it even more difficult to address vital global issues. Indeed, even as we need more international cooperation on multiple fronts, we are facing the specter of a new Cold War that could see the world fragment into rival economic blocs. This would be a collective policy mistake that would leave everyone poorer and less secure. *Source: International Monetary Fund*

### US and Chinese Officials Discussed Climate, Economy, and Relationship

U.S. Treasury Secretary Janet Yellen met on January 18, 2023 with Vice Premier Liu He in Zurich and pledged an effort to manage differences and “prevent competition from becoming anything ever near conflict” as the two nations try to thaw relations. A U.S. Treasury readout of the 2 1/2-hour meeting says the two agreed that the U.S. and China would cooperate more on issues around financing for battling climate change and work to support “developing countries in their clean energy transitions.” The readout also indicates Yellen plans to travel to China and welcomes her counterparts to the U.S. in the near future. *Source: AP News*

### US—China Trade is Close to a Record, Defying Talk of Decoupling

Amid harsh national security rhetoric in the US and concerns about decoupling, trade between the U.S. and China is on track to set records, a sign of durable linkages between the world's major

economies. According to US official data up to November 2022, when the final report is released on February 7, 2023, imports and exports year 2022 will add up to an all-time high, or at least extremely close to it. China just released full-year statistics showing record trade of over $760 billion. Positive developments recently include plans for a face-to-face meeting between US President Joe Biden and Chinese leader Xi Jinping in November 2022 and further high-level linkages, such as US Secretary of State Antony Blinken's visit to China this year. But it's unlikely that China's position on Taiwan and the South China Sea, as well as the US's vigorous measure to restrict China access to key semiconductor technology, will be quickly resolved. This demonstrates how deeply entwined the two economies remain — even as the US wants to slow China's rise and China seeks to challenge the US's global influence. *Source: Bloomberg*

**អត្ថបទស្រាវជ្រាវ**

# ច្រវាក់តម្លៃសកល ទីក្រុង និងបរិក្ខារកម្មទីក្រុង៖ ដំណាក់កាលបន្ទាប់នៃការរីកចម្រើនសម្រាប់តំបន់អាស៊ាននិងអាស៊ីបូព៌ា*

**ថាងកាវ៉ាលូ សនជ្រេ មុហ្កាន**
ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ព្រះរាជាណាចក្រកម្ពុជា
វិទ្យាស្ថាន Jeffrey Cheah សម្រាប់តំបន់អាស៊ីអាគ្នេយ៍ នៃសាកលវិទ្យាល័យសាន់វេយ៍
វិទ្យាស្ថានពាណិជ្ជកម្មអន្តរជាតិ សាកលវិទ្យាល័យអាដេឡែដ

**គិម៉ុរ៉ា ហ្វុគុណារិ**
សាកលវិទ្យាល័យខេយ៉ូ
វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាននិងអាស៊ីបូព៌ា

**ណារេចូកូ ឱអូនីស៊ីស**
វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាននិងអាស៊ីបូព៌ា

## សេចក្តីសង្ខេប

នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងស្វែងយល់ពីផលប៉ះពាល់នៃបរិក្ខារកម្មទីក្រុងលើការអភិវឌ្ឍ និងបរិវត្តកម្មខ្សែច្រវាក់តម្លៃសកល នៅក្នុងតំបន់អាស៊ាននិងអាស៊ីបូព៌ា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ និងការបែងចែកសកម្មភាពផលិតកម្មនិងសេវាកម្ម តាមរយៈបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន។ អត្ថបទស្រាវជ្រាវនេះបង្ហាញពីសារសំខាន់នៃបរិក្ខារកម្មទីក្រុង ដើម្បីរក្សានិងថែទាំកម្លាំងពលកម្មជំនាញនៅក្នុងទីក្រុងសំខាន់ៗ សំដៅជំរុញកំណើនសេដ្ឋកិច្ច។ សម្រាប់តំបន់អាស៊ីនិងអាស៊ាន យើងបានប្រើប្រាស់ទិន្នន័យកម្រិតទីក្រុង ពីការិយាល័យប្រជាជន នៃនាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម របស់អង្គការសហប្រជាជាតិ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងទីក្រុងកម្មខ្សែច្រវាក់តម្លៃសកល និងបរិក្ខារកម្មទីក្រុង។ អត្ថបទស្រាវជ្រាវនេះបានគូសបញ្ជាក់ថា ដំណាក់កាលបន្ទាប់នៃកំណើនក្នុងអាស៊ាន នឹងត្រូវបានជំរុញដោយភាពប្រកួតប្រជែងរបស់ទីក្រុងនានា ទាក់ទងនឹងការទាក់ទាញ និងរក្សាបាននូវកម្លាំងពលកម្មជំនាញ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ការអភិវឌ្ឍបរិក្ខារកម្មទីក្រុងប្រកបដោយគុណភាព និងការបង្កើតការតភ្ជាប់ទៅកាន់ទីក្រុងក្នុងតំបន់ និងពិភពលោក។

*ពាក្យគន្លឹះ៖ ខ្សែច្រវាក់តម្លៃសកល បរិវត្តកម្មរចនាសម្ព័ន្ធ និងបរិក្ខារកម្មទីក្រុង*

* អត្ថបទស្រាវជ្រាវជាភាសាខ្មែរត្រូវបានបកប្រែក្រៅផ្លូវការ ដើម្បីចៀសវាងកំហុសលើខ្លឹមសារអត្ថបទ សូមអានអត្ថបទដើមជាភាសាអង់គ្លេស។

## សេចក្ដីផ្ដើម

ខ្សែច្រវាក់តម្លៃ និងបណ្ដាញតម្លៃផលិតកម្មក្នុងតំបន់និងសកល ជាធាតុដ៏សំខាន់ និងជាកត្តាជំរុញដ៏ចំបាច់សម្រាប់កំណើនសេដ្ឋកិច្ច និងសមាហរណកម្មនៅក្នុងតំបន់អាស៊ីបូព៌ានិងអាស៊ាន។ ឥទ្ធិពលរបស់ខ្សែច្រវាក់តម្លៃសកលលើសកម្មភាពផលិតកម្មសេវាកម្មនៅអាស៊ីបូព៌ា និងលើការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ មានសារសំខាន់ណាស់ (Kimura, ២០១៨; Baldwin, ២០១១, ASEAN Integration Report, ASEAN Secretariat, ២០១៩)។

ភ័ស្តុតាងថ្មីៗបង្ហាញថា តម្លៃបន្ថែមក្នុងស្រុក (DVA) ក្នុងការនាំចេញនៃប្រទេសសមាជិកអាស៊ាន គឺមានកម្រិតខ្ពស់ និងមានស្ថិរភាពល្អ ចាប់តាំងពីឆ្នាំ២០១០ មកម្ល៉េះ (ASEAN Integration Report, ASEAN Secretariat, ២០១៩)។ តម្លៃបន្ថែមក្នុងស្រុកនៃការនាំចេញមានប្រហែល ៤៧% សម្រាប់ប្រទេសសិង្ហបុរី រហូតដល់ ៩០,៣% សម្រាប់ប្រទេសប្រ៊ុយណេ។ តម្លៃបន្ថែមពីបរទេស (FVA) ក្នុងការនាំចេញគឺមានប្រមាណ ៣៩% សម្រាប់ប្រទេសសិង្ហបុរី និងនៅកម្រិតទាបជាង ៦,៧% សម្រាប់ប្រទេសប្រ៊ុយណេ។

តំបន់អាស៊ីបូព៌ានិងអាស៊ាន កំពុងឆ្លងកាត់បរិវត្តកម្មរចនាសម្ព័ន្ធដ៏សំខាន់មួយ កើតចេញពីថាមវន្តនៃខ្សែច្រវាក់តម្លៃតំបន់និងសកល។ បរិវត្តកម្មនេះបាននិងកំពុងជំរុញឱ្យមានសមាហរណកម្មសេដ្ឋកិច្ច និងសមាហរណកម្មតំបន់កាន់តែស៊ីជម្រៅថែមមួយកម្រិតទៀត។ ជាការពិតណាស់ បណ្ដាញខ្សែច្រវាក់តម្លៃសកលកំពុងជំរុញឱ្យមានការផ្លាស់ប្ដូរសេដ្ឋកិច្ចនៅតំបន់អាស៊ីបូព៌ា ទាំងតម្រូវការនៃភាពជាអ្នកប្រើប្រាស់មានសក្ដានុពល និងផលប៉ះពាល់លើការផ្គត់ផ្គង់ កើតចេញពីដំណើរការបែងចែក និងការប្រមូលផ្ដុំ ដែលធ្វើឱ្យមានសមាហរណកម្មកាន់តែស៊ីជម្រៅនៃបណ្ដាញផលិតកម្មក្នុងតំបន់និងពិភពលោក ទាំងផ្នែកផលិតកម្មនិងសេវាកម្ម។ បរិវត្តកម្មនៃច្រវាក់តម្លៃសកល កើតចេញពីបច្ចេកវិទ្យាឌីជីថល និងទូរគមនាគមន៍ បាននិងកំពុងបង្កើតកាលានុវត្តភាពសេដ្ឋកិច្ចថ្មី ហើយទន្ទឹមនឹងនោះ ក៏កំពុងជំរុញឱ្យមានការបំផ្លិចបំផ្លាញបែបច្នៃប្រឌិតកាន់តែច្រើន នៅក្នុងសេដ្ឋកិច្ចតំបន់អាស៊ីបូព៌ានិងអាស៊ាន។

ឥទ្ធិពលនៃច្រវាក់តម្លៃសកល មិនមែនជាបាតុភូតថ្មីនោះទេនៅតំបន់អាស៊ី។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០មក ក្រុមហ៊ុនលក់រាយរបស់សហរដ្ឋអាម៉េរិក និងក្រុមហ៊ុនម៉ាកយីហោធំៗបានចាប់ផ្ដើមធ្វើប្រតិបត្តិការលើអាជីវកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មរបស់ពួកគេនៅឯក្រៅប្រទេស (Gereffi ២០១៣) ដើម្បីស្វែងរកអត្ថប្រយោជន៍ចេញពីតម្លៃពលកម្មថោក។ ទោះជាយ៉ាងណានៅពេលថ្មីៗនេះ ជំហាននៃបរិវត្តកម្មខ្សែច្រវាក់តម្លៃសកលមានការរីកចម្រើនយ៉ាងខ្លាំង ទាំងក្នុងទម្រង់នៃល្បឿន ទំហំភាពស៊ីជម្រៅ និងវិសាលភាពនៃអន្តរកម្មសកល (Elms & Low ២០១៣)។ ដំណើរការនៃការបែងចែកនេះ កាន់តែមានសន្ទុះខ្លាំងចាប់ពីឆ្នាំ២000 លើសពីវិស័យផលិតកម្ម ទៅវិស័យសេវាកម្ម ដូចជាគណនេយ្យ នីតិវិធីវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលទូរស័ព្ទជាដើម (Gereffi & Sturgeon ២០១៣)។ ខ្សែច្រវាក់តម្លៃសកល ក៏បានរីកសាយភាយតាមភូមិសាស្ត្រដែលពាក់ព័ន្ធនឹងប្រទេសដែលមានវិសាលភាពកាន់តែទូលំទូលាយ ពីតំបន់មួយទៅតំបន់មួយ និងមានលក្ខណៈជាស្ថាប័ន នៅក្នុងបណ្ដាញនៃអន្តរក្រុមហ៊ុន ដែលកាន់តែមានភាពស្មុគស្មាញ និងច្រើនស្រទាប់ នៅទូទាំងពិភពលោក។ ការកំណត់រចនាសម្ព័ន្ធផលិតកម្មនេះ ដែលបានក្លាយជាលក្ខណៈពិសេសសំខាន់បំផុតនៃសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ន (De Backer, De Lombaerde & Iapadre ២០១៨; OECD ២០១៣) ត្រូវបានជំរុញដោយវឌ្ឍនភាពនៃបច្ចេកវិទ្យា ភាពជឿនលឿនក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ដែលនាំឱ្យមានការថយចុះគួរឱ្យកត់សម្គាល់នៃតម្លៃពាណិជ្ជកម្ម ភាពទូលំទូលាយជាងមុននៃគោលនយោបាយថ្នាក់តំបន់និងថ្នាក់ជាតិដែលឆ្ពោះទៅរករំហូរពាណិជ្ជកម្មនិងការវិនិយោគដោយសេរី និងការបើកទូលាយនៃសេដ្ឋកិច្ចដែលកំពុងរីកចម្រើន ជាពិសេសនៅក្នុងប្រទេសចិននិងឥណ្ឌា (Kimura ២០១៨; Baldwin ២០១២, ២០១៣; De Backer, De Lombaerde & Iapadre ២០១៨)។

បរិវត្តកម្មចម្បងនៅក្នុងខ្សែច្រវាក់តម្លៃសកល គឺភាពស៊ីជម្រៅ និងកម្រិតនៃការធ្វើសមាហរណកម្ម ព្រមទាំងអន្តរកម្មនៃភាពពឹងពាក់គ្នារវាងសេដ្ឋកិច្ចក្នុងតំបន់ និងសកម្មភាពកម្រិតសកលនានា។ ការផ្លាស់ប្តូរយ៉ាងសំខាន់មួយលេចឡើងនៅក្នុងពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោកៈ គឺការផ្លាស់ប្តូរពីការធ្វើពាណិជ្ជកម្មលើទំនិញចុងក្រោយ ទៅជាការធ្វើពាណិជ្ជកម្មលើផ្នែក និងគ្រឿងបង្គុំនៃទំនិញ។ ការបំបែកភូមិសាស្ត្រនៃការប្រមូលផ្តុំនៃផលិតកម្ម ក៏បានពង្រឹងភាពពឹងពាក់គ្នាផ្នែកសេដ្ឋកិច្ច រវាងប្រទេស និងដែនដីជុំវិញពិភពលោក ពិសេសទាក់ទងនឹងលំហូរនៃការវិនិយោគ និងការបង្កើនលំហូរនៃទំនិញកម្រិតមធ្យម។ អង្គការពាណិជ្ជកម្មពិភពលោក (WTO) និង IDP-JETRO (២០១១) បានប៉ាន់ប្រមាណថា ពាណិជ្ជកម្មទំនិញកម្រិតមធ្យមក្នុងឆ្នាំ ២០០៩ មានជាង៥០% នៃពាណិជ្ជកម្មទំនិញដែលមិនមែនជាឥន្ធនៈ។ ការសិក្សារបស់អ្នកស្រាវជ្រាវឈ្មោះ Gurría (២០១៥) បានរកឃើញថា ចំណែកនៃពាណិជ្ជកម្មលើធាតុផ្សំកម្រិតមធ្យម មានកម្រិតខ្ពស់ជាងនេះ (ប្រមាណជាង៥០% នៃពាណិជ្ជកម្មទំនិញ និងស្ទើរតែ៧០% នៃពាណិជ្ជកម្មសេវាកម្ម) និងប្រហែលពីរភាគបី បើតាមការសិក្សារបស់អ្នកស្រាវជ្រាវឈ្មោះ Johnson និង Noguera (២០១២)។ សៀវភៅបោះពុម្ពចុងក្រោយបង្អស់របស់លោក Baldwin (២០១៦)ស្តីពីសកលភាវូបនីយកម្ម បានបង្ហាញថា 'ពាណិជ្ជកម្មសតវត្សទី២១' គឺជាការរីកលូតលាស់នៃការធ្វើពាណិជ្ជកម្មនៃផ្នែកនិងគ្រឿងបង្គុំ រួមជាមួយនឹងបន្លាស់ទីជាអន្តរជាតិនៃបរិក្ខារផលិត បុគ្គលិក និងចំណេះដឹង។

ទិដ្ឋភាពមួយទៀត នៃបរិវត្តកម្មនៃខ្សែច្រវាក់តម្លៃសកល គឺកម្រិតនៃកំណើនសកម្មភាពផ្នែកសេវាកម្ម និងការតភ្ជាប់នៅក្នុងដំណើរការផលិតកម្ម។ ដោយសារតែការរីកចម្រើន កើតចេញពីផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ការបំបែកដំណើរការផលិតកម្មនៅក្នុងនិងតាមបណ្តាប្រទេសនានា មានការលូតលាស់ទាំងកម្រិតនៃកំណើន និងអន្តរកម្មនៃភាពពឹងពាក់គ្នាក្នុងដំណើរការផលិតកម្ម រវាងសកម្មភាពផលិតកម្ម និងសេវាកម្ម។ សេវាកម្មបាននិងកំពុងដើរតួជាធាតុចូល និងការតភ្ជាប់ក្នុងដំណើរការខ្សែច្រវាក់តម្លៃ ដែលធ្វើឱ្យវាក្លាយជា "ការតភ្ជាប់នៃខ្សែច្រវាក់ផ្គត់ផ្គង់" (Low ២០១៣) ឬសំដៅដល់ 'សេវានីយកម្ម' នៃផលិតកម្ម (Hoekman និង Shepherd ២០១៧, Thangavelu et al, ២០១៨)។ នៅក្នុងសិក្ខាសាលាស្តីពីតួនាទីនៃសេវាកម្មក្នុងផលិតកម្ម និងពាណិជ្ជកម្មអន្តរជាតិ លោក Jones និងលោក Kierzkowski (១៩៩០) បានអះអាងយ៉ាងជឿជាក់ថា ល្បឿន និងប្រសិទ្ធភាពក្នុងប្រតិបត្តិការនៃការតភ្ជាប់សេវាកម្ម ប្រាកដជាមានផលប៉ះពាល់លើកម្រិតនៃការបែងចែកផលិតកម្ម ហើយថាផលចំណេញកើតពីសេរីភាវូបនីយកម្មផ្នែកសេវាកម្ម អាចកើតមានក្នុងទម្រង់ជាការចូលរួមកាន់តែច្រើននៅក្នុងដំណើរការផលិតកម្ម។ លោក Baldwin (២០១៦) បានចាត់ទុកសេវាកម្ម ដែលរួមមានទូរគមនាគមន៍ ការដឹកជញ្ជូននិងភស្តុភារ ហិរញ្ញវត្ថុទាក់ទងនឹងពាណិជ្ជកម្ម និងការជម្រះបញ្ជីពន្ធគយ គឺពិតជាមានភាពចាំបាច់ក្នុងការសម្របសម្រួលផលិតកម្មដែលត្រូវបានបំបែក ឬមិនប្រមូលផ្តុំ។ សេវាកម្មនៅក្នុងខ្សែច្រវាក់តម្លៃសកល មានសារសំខាន់កាន់តែខ្លាំង នៅក្នុងចំណែកនៃសេវាកម្ម ដែលកើតមាននៅក្នុងពាណិជ្ជកម្មតម្លៃបន្ថែម (value-added trade) ដែលមានទំហំច្រើនជាង៤០% ក្នុងឆ្នាំ ២០០៩ កើនឡើងពី៣០% ធៀបនឹងឆ្នាំ១៩៨៥ (Heuser និង Mattoo ២០១៧)។ ការសិក្សាថ្មីៗ ដោយលោក Thangavelu et al (២០១៨) ក៏បានរំលេចឱ្យឃើញពីផលប៉ះពាល់នៃសេវានីយកម្មនៅក្នុងតំបន់អាស៊ី ដែលបង្ហាញថា កម្រិតនៃសេវានីយកម្មក្នុងសកម្មភាពផលិតកម្មក្នុងតំបន់អាស៊ានបានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

បរិវត្តកម្មនៃខ្សែច្រវាក់តម្លៃសកលកាលពីពេលថ្មីៗនេះ ក៏បានបង្ហាញពីសារសំខាន់នៃកំណើនដែលគ្មានតុល្យភាពនៅក្នុង និងរវាងប្រទេសនានា កើតចេញពីការឆ្លើយតបផ្នែកឧស្សាហកម្ម និងការប្រកួតប្រជែងដែលមិនមានតុល្យភាពគ្នានៅតាមទីតាំងជាក់លាក់ក្នុងប្រទេស និងរវាងប្រទេសនានា។ ទិដ្ឋភាពគន្លឹះ ដែលបង្ហាញពីវិសមភាពរវាងទីតាំងនានានៅក្នុងប្រទេសមួយ គឺកំណត់បានតាមរយៈរបៀបដែលទីក្រុងសំខាន់នីមួយនៅក្នុងប្រទេសនោះធ្វើការស្រូបយក ប្រើប្រាស់ និងផ្សព្វផ្សាយនូវបច្ចេកវិទ្យាសំខាន់ៗ និងភារកិច្ចច្បាស់លាស់ ជូនដល់ក្រុមហ៊ុន និងកម្មករ ដែលជាការឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៅក្នុងខ្សែច្រវាក់តម្លៃសកល ។

ការឆ្លើយតបប្រកបដោយភាពប្រកួតប្រជែង គឺកើតចេញពីភាពបត់បែនរបស់កម្មករជំនាញក្នុងការ "បែងចែក" (ក)បច្ចេកវិទ្យា និងសកម្មភាពផ្សេងៗ (ខ)ហេដ្ឋារចនាសម្ព័ន្ធដែលពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យា រួមមានសួនវិទ្យាសាស្ត្រ សាកលវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវ និង (គ)ហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា បរិក្ខារកម្មទីក្រុង រួមមានសណ្ឋាគារ ភោជនីយដ្ឋាន បណ្ណាល័យ តូបអ៊ីនធឺណិត និងការតភ្ជាប់នានា ទាំងទន់និងរឹង។

ការសិក្សាថ្មីមួយ ដោយលោក Glaeser et. al (២០១៥) បានលើកឡើងពីសារសំខាន់នៃទីក្រុង ក្នុងការបង្កើតបណ្តាញទីក្រុង ដែលអាចបង្កើតនវានុវត្តន៍ និងសហគ្រិនភាព សំដៅជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុក និងក្នុងតំបន់។ ការបង្កើតបណ្តាញទីក្រុង តាមរយៈការធ្វើបរិក្ខារកម្មទីក្រុង នឹងជួយបង្កើនទំហំសេដ្ឋកិច្ចសកល តាមរយៈការធ្វើនវានុវត្តន៍ក្នុងវិស័យសេវាកម្ម និងការតភ្ជាប់សកល បើទោះបីជាការផ្តល់ត្រឡប់មកវិញនៃប្រាក់ចំណូលក្នុងស្រុកអាចធ្លាក់ចុះដោយសារការជួសគ្នា រវាងការរស់នៅប្រកបដោយភាពស៊ីវិល័យជាងមុន ជាមួយនឹងការកកស្ទះកាន់តែខ្លាំងនៅក្នុងទីក្រុង។ តែអ្វីដែលទទួលបានមកវិញនោះគឺការបង្កើតបណ្តាញទីក្រុង ដែលទាក់ទាញកម្មករជំនាញឱ្យផ្លាស់ទីមករស់នៅក្នុងទីក្រុងធំៗ ដោយសារតែប្រាក់ចំណូលខ្ពស់ទទួលបានពីការបង្កើតបណ្តាញទីក្រុងសកលនេះ។

បណ្តាញទីក្រុងនិងការប្រមូលផ្តុំ មិនត្រឹមតែមានការប៉ះពាល់ទៅលើនវានុវត្តន៍នៃសេវាកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏មានផលប៉ះពាល់លើសកម្មភាពផលិតកម្មផងដែរ ដោយសារតែការធ្វើបរិក្ខារកម្មទីក្រុង ក៏បង្កើតសេដ្ឋកិច្ចវិមាត្រ និងចំណេះដឹងដ៏សំបូរបែប ដល់ក្រុមហ៊ុននានា ក្នុងការធ្វើនវានុវត្តន៍ និងបង្កើនសកម្មភាពសហគ្រិនភាពរបស់ពួកគេ (Chen et al. ២០២០)។ ការសិក្សាថ្មីមួយ អំពីអាស៊ី ដោយអ្នកស្រាវជ្រាវឈ្មោះ Chen et al. (២០២០) បានគូសបញ្ជាក់ពីផលប៉ះពាល់នៃការប្រមូលផ្តុំតាមរយៈការបង្កើតវត្តមាននៃសាកលវិទ្យាល័យលំដាប់កំពូលនៅតាមទីក្រុងនៅក្នុងតំបន់អាស៊ី ដែលចូលរួមចំណែកដល់ការបង្កើនកម្រិតប្រសិទ្ធភាពនៃសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ របស់ក្រុមហ៊ុននានា។

នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងស្វែងយល់ពីការអភិវឌ្ឍ និងបរិវត្តកម្មនៃច្រវាក់តម្លៃសកល នៅក្នុងតំបន់អាស៊ីនិងអាស៊ីប៉ូព៌ា ទាក់ទងនឹងការអភិវឌ្ឍជំនាញ ការបែងចែកសកម្មភាពផលិតនិងផ្តល់សេវាកម្ម ដោយសារការកើនឡើងនៃបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន និងសារសំខាន់នៃបរិក្ខារកម្មទីក្រុង ក្នុងការរក្សា និងថែទាំកម្លាំងពលកម្មជំនាញនៅក្នុងទីក្រុងសំខាន់ៗ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ សម្រាប់តំបន់អាស៊ី និងអាស៊ាន យើងបានប្រើប្រាស់ទិន្នន័យកម្រិតទីក្រុង ពីការិយាល័យប្រជាជននៃនាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម របស់អង្គការសហប្រជាជាតិ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងទីក្រុង ខ្សែច្រវាក់តម្លៃសកល និងបរិក្ខារកម្មទីក្រុង។ លទ្ធផលនៃការសិក្សារបស់យើងបង្ហាញពីសារសំខាន់នៃទីក្រុងនិងបរិក្ខារកម្មទីក្រុង ដែលជាកត្តាដ៏សំខាន់ក្នុងការជួយស្តារឡើងវិញក្នុងអំឡុងពេលជំងឺរាតត្បាត និងក្រោយជំងឺរាតត្បាត។ មជ្ឈមណ្ឌលទីក្រុង និងទីប្រជុំជននឹងក្លាយជាទីតាំងគន្លឹះក្នុងការអភិវឌ្ឍ ទាក់ទាញ និងផ្តល់និរន្តរភាពនៃបច្ចេកវិទ្យាឌីជីថល ព្រមទាំងរក្សាកម្រិតនៃការបើកចំហដែលចាំបាច់សម្រាប់ការស្តារឡើងវិញចេញពីជំងឺរាតត្បាត។

ផ្នែកបន្ទាប់នឹងពិភាក្សាអំពីបរិវត្តកម្មនៃខ្សែច្រវាក់តម្លៃសកល នៅតំបន់អាស៊ីនិងអាស៊ាន។ ផ្នែកទី៣ នឹងផ្តល់ជាទិដ្ឋភាពនៃការប្រមូលផ្តុំនៃចំនួនប្រជាជន និងនិន្នាការនៃទីក្រុងនានានៅតំបន់អាស៊ី។ នៅក្នុងផ្នែកទី៤ យើងនឹងផ្តល់នូវទ្រឹស្តីបទ នៃបរិវត្តកម្មនៃខ្សែច្រវាក់តម្លៃសកល និងផលប៉ះពាល់នៃការបែងចែកខ្សែច្រវាក់តម្លៃសកល។ នៅក្នុងផ្នែកទី៤ផងដែរ យើងនឹងផ្តល់ការពិភាក្សាអំពីជំនាញ និងការបែងចែកជំនាញទៅក្នុងកិច្ចការនីមួយៗ។ ដោយឡែក ផ្នែកទី៥ នឹងផ្តល់ការពិភាក្សាអំពីគោលនយោបាយទាក់ទងនឹងការស្តារឡើងវិញចេញពីជំងឺរាតត្បាត។

*សូមស្កេន QR កូដ ឬចុចលើតំណភ្ជាប់ដើម្បីអានខ្លឹមសារទាំងស្រុង*

*Working Paper No. 001/2023*

*© រក្សាសិទ្ធិដោយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ។ ខ្លឹមសារនៃអត្ថបទនេះជាគំនិតនិងទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ និងមិនបញ្ជាំងពីទស្សនៈរបស់ក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធឡើយ។*

Research Article

# GLOBAL VALUE CHAIN, CITIES AND URBAN AMENITIES: NEXT STAGE OF GROWTH FOR ASEAN AND EAST ASIA

**Shandre Mugan Thangavelu**
Advisor to Ministry of Commerce, Cambodia
Jeffrey Cheah Institute for Southeast Asia, Sunway University
Institute for International Trade, University of Adelaide

**Fukunari Kimura**
Keio University
Economic Research Institute for ASEAN and East Asia

**Dionisius A. Narjoko**
Economic Research Institute for ASEAN and East Asia

## Abstract

In this paper, we explore the impact of urban amenities on the development and transformation of GVC in ASEAN and East Asia in terms of skills development and the unbundling of manufacturing and services activities due to telecommunication and information technologies. The chapter highlights the importance of urban amenities to retain and maintain skill labour in the key cities to drive economic growth. We used the city level data for Asia and ASEAN from UN, Department of Economic and Social Affairs, Population Division, to understand the relationship among cities, GVC and urban amenities. The paper highlights that the next stage of growth in ASEAN will be driven by the competitiveness of the cities in terms of attracting and retaining skilled labour, developing the telecommunication infrastructure, developing quality urban amenities and creating the connectedness to regional and global cities.

*Key words: GVC, Structural Transformation and Urban Amenities*

## Introduction

Regional and Global production value chain and network are important features as well as the key driver of economic growth and integration in East Asia and ASEAN. The impact of GVC on the East Asian manufacturing and services activities and hence on its economic development is quite significant (Kimura, 2018; Baldwin, 2011, ASEAN Integration Report, ASEAN Secretariat, 2019). Recent evidence shows that DVA (domestic value-added) in the exports of ASEAN Member States have been relatively high and stable since 2010 (ASEAN Integration Report, ASEAN Secretariat, 2019). The DVA of exports ranges around 47% for Singapore to 90.3% for Brunei. The FVA (foreign value-added) in exports is at 39% for Singapore and at a lower range of 6.7% for Brunei.

East Asia and ASEAN are undergoing significant structural transformation due to the dynamism of regional and global value chain. It is driving deeper economic and regional integration. In fact, the global value chain network is driving the economic transformation of East Asia from both the demand in terms of forward-looking and dynamic consumerism, and supply-side effects of fragmentation and agglomeration integrating deeper regional and global production networks in both manufacturing and services. The transformation of GVC from digital and telecommunication technologies are creating new economic opportunities and also are inducing greater creative-destructions in the respective East Asian and ASEAN economies.

The effects of GVC is not a new phenomenon in Asia. Since 1970s, US retailers and big brand-name companies started offshoring their labour-intensive activities overseas (Gereffi 2013) in search of cheap labour advantages. However, in recent GVC transformation, the pace of GVC has accelerated in terms of the speed, scale, depth and breadth of global interaction (Elms and Low 2013). The fragmentation process has intensified since 2000s beyond manufacturing sector to services such as accounting, medical procedure and call centres (Gereffi and Sturgeon 2013). GVCs have also proliferated geographically involving broader countries from various regions and organizationally manifest in more complex and multi-layer inter-firm networks across the globe. This production configuration, which has become the most important feature of global economy today (De Backer, De Lombaerde, and Iapadre 2018; OECD 2013), is driven by technological progress, advance in transport and logistic sector that lead to significant decline in trade costs, a more liberal regional and national policies toward freer trade and investment flows, and the opening up of emerging economies, especially in China and India (Baldwin 2013; Humphrey and Schmitz 2002; De Backer, De Lombaerde, and Iapadre 2018; Amador and Cabral 2016; Baldwin 2012; Athukorala 2011).

The key transformation of the GVC is the depth and degree of integration and inter-dependency of the regional economies to global activities. There is a significant shift in the trade patterns in regional and global economy from exchange of final goods to trade in parts and components. Geographic dispersion of production has substantially increased economic interdependency among economies around the world especially in terms of investment flow and intensification of flow in intermediate goods. WTO and IDP-JETRO (2011) estimated that trade in intermediate goods in 2009 represents more than 50% of non-fuel merchandise trade. The share of intermediate input trade is found even higher (over 50% of goods trade and almost 70% of services trade) in Gurría (2015) and roughly two-third in Johnson and Noguera (2012). In his latest book on the new globalization, Baldwin (2016) describes the ‘21$^{st}$ century trade’ as growing exchange

of parts and components along with international movement of production facilities, personnel and know-how.

The other aspect of the GVC transformation is the level of growth of service activities and linkages in the production process. The fragmentation of production process within and across countries due to technological advancement from telecommunication and information technologies have intensified the growth and inter-dependency of production processes between manufacturing and service activities. Services serve as inputs and linkages across value chains process, making it the 'glue of supply chains' (Low 2013) or sometimes refer to 'servicification' of production (Hoekman and Shepherd 2017). In the seminar work on the role of services in production and international trade, Jones and Kierzkowski (1990) firmly argues that the speed and efficiency with which service links operate clearly have a bearing on the optimal degree of fragmentation and that the gains from service liberalization may exist in form of greater participation in production process. Baldwin (2016) regards services such as telecommunication, transport and logistics, trade-related finances and custom clearance necessary to coordinate fragmented production. The importance of services in GVC is manifest in large and increasingly share of service in value -added trade, accounting for more than 40% in 2009 rising from 30% in 1985 (Heuser and Mattoo 2017). The impact of servicification of the Asia is also reflected by the recent study by Thangavelu et. al (2018) indicating that the degree of servicification of manufacturing activities in ASEAN has increased over the years.

The recent transformation of the GVC also highlights the importance of unbalance growth within and between countries due to the unbalance industrial and competitive responses of the specific regions within countries and also between countries. The key dimension of regional disparity within the economy is based on how responsive key cities are in the domestic economy to absorb, diffuse and disseminate key technologies and specific tasks to firms and workers in response to the dynamic shifts in the GVC. The key competitive responses are driven by the flexibility of skilled workers to 'unbundle' the technologies and activities; technology-intensive infrastructure such as science parks, universities, research centres; and the social infrastructure such as urban amenities in hotels, restaurants, libraries, internet café, and soft and hard connectivity.

Recent study by Glaeser et. al (2015) highlights the importance of cities to create urban networks that creates innovation and entrepreneurship to spur the economic growth of the domestic economy and region. The urban networks through urban amenities increase global economies of scale through innovation in services and global linkages, although the return on local returns could decline due to the trade-off of urban congestion and living. In turn, the returns of urban networks to attract skilled workers to move and live in large and mega cities due to the higher returns from global urban networks.

The impact of urban network and agglomeration is not only on the innovation of services, but also on the manufacturing activities as urban amenities also create the economies of scale and knowledge spillovers for firms to innovate and increase their entrepreneurial activities (Chen et. al, 2020). Recent study of Asia by Chen at. al (2020) highlights the agglomeration effects through presence of top-tier universities at the Asian cities in raising the effectiveness of firm level R&D activities.

In this chapter, we explore the development and transformation of GVC in Asia and East Asia in terms of skills development, unbundling of manufacturing and services activities due to telecommunication and information technologies, and the importance of urban amenities to retain and maintain skill labour in the key cities to drive economic growth. We used the city level data for Asia and ASEAN from UN, Department of Economic and Social Affairs, Population Division, to understand the relationship between cities, GVC and urban amenities. The results of our study indicate the importance of cities and urban amenities as important leverages for pandemic and post-pandemic recovery. Cities and urban centres will be the key to develop, attract, and sustain digital technologies and maintain the degree of openness necessary for the pandemic recovery.

The next section will discuss the GVC transformation in Asia and ASEAN. Section 3 will provide the population agglomeration and trends of cities in Asia. In section 4, we will provide the topology of GVC transformation and 'unbundling' effects of GVC. We will provide discussions on skill and unbundling of skills to tasks in Section 4. Section 5 will provide the policy discussion in terms of the pandemic recovery.

*Please scan QR code or click the link to reach the full content of this article*

*Working Paper No. 001/2023*

*© All use subject to Trade Training and Research Institute (TTRI). The views expressed here are of the authors and do not reflect that of the Ministry of Commerce and their affiliated organizations.*

# ABOUT THE iTRADE BULLETIN

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


**Honorable President**
H.E. Mr. PAN Sorasak

**Editorial Board**
- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Advisor**
- H.E. Mr. SIM Sokheng
- H.E. Mr. SAMHENG Bora
- H.E. Mr. PENN Sovicheat
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**Technical Team**
- Mr. PAO Phireak
- Ms. PHAL Yita
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Mr. LY Rithy
- Mr. NY Atykunn
- Mr. KHAM Chansopheak

**Supporting Team Member**
- Ms. CHEA Kunlak
- Mr. SE Sokunvathna
- Ms. VAT Vanpanhapich
- Ms. VUTHY Sophanika


# ANNOUNCEMENT

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

**Topics Covered:**

- International trade and logistics / trade laws;
- Digital economy / e-commerce;
- Economics and economic laws;
- Value added supply chains and logistics; and
- Facilitate the green business transition

**Categories:**

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial


## Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla,
Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.info | @ttrimoccambodia